002/19-09-2007-ECCC/TC
E1/247

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2015
ម៉ោង (Time/Heure) : 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បត្តិ៍ ទី ០៨ ខែ មករា ឆ្នាំ ២០១៥

## **សវនាការលើកស្តុតាង - ថ្ងៃ ២២៨**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Robynne CROFT**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Robynne CROFT, លោក Matthew Jordan Ekundayo Mccarthy |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង ប៊ុនឃាង, លោក សេង លាង, លោក ស្រ៊ា រតនៈ, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា, លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជអង្គ, លោកស្រី Marie GUIRAUD, លោក Yiqiang LIU, លោក ឡោ ជុនធី, លោក ហុង គឹមសួន, លោក វ៉េន ពៅ, លោកស្រី ស៊ិន សុវន, លោក Mahesh RAI |
| សាក្សី/ដើមបណ្ដឹង៖ មាស សុខា ហៅ ថ្លាង (2-TCW-936) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុធាវី |
| ផ្សេងៗ៖ លោក MEACH Sovanna, លោក NOU Monoroath, លោក Laurent SOULARD, កញ្ញា Sara ERJAVEC |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖១៣:៥៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.២០ | បញ្ចប់ម៉ោង៖ ១០:៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៥០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ២ ម៉ោង និង ៤០ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| អង្គជំនុំជម្រះប្រកាសបើកសវនាការ | អង្គជំនុំជម្រះ | ០៩:០១ | ០៩.០៩ |
| ការជំទាស់ទៅលើវត្តមាន និងការរៀបចំកន្លែងអង្គុយថ្មីរបស់មេធាវីប្រចាំការ នៅក្នុងសវនាការ | មេធាវីការពារក្ដី ខៀវ សំផន<br>មេធាវីការពារក្ដី នួន ជា<br>ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ០៩.១០<br>០៩.២៤<br>០៩.២៨<br>០៩.៣២<br>០៩.៣៤ | ០៩.២៤<br>០៩.២៨<br>០៩.៣២<br>០៩.៣៤<br>០៩.៤១ |
| អង្គជំនុំជម្រះសួរបញ្ជាក់ពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ | អង្គជំនុំជម្រះ<br>ខៀវ សំផន | ០៩.៤៣<br>០៩.៤៥ | ៩.៤៥<br>៩.៤៦ |
| សំណើរបស់សហមេធាវីនាំមុខសុំឱ្យទទួលយកឯកសារផែនទី ជាភស្ដុតាង | អង្គជំនុំជម្រះ<br>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវីការពារក្ដី នួន ជា | ០៩.៤៧ | ០៩.៥៨ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅកាន់សាក្សី មាស សុខា (2-TCW-936) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១០.០៤<br>១០.៥០ | ១០.៥០<br>១២.០៥ |
| ការជំទាស់ទៅលើការអនុវត្តដែលឲ្យសាក្សីអានកំណត់ហេតុនៃការស្តាប់ចម្លើយមុនការផ្តល់សក្ខីកម្ម | មេធាវីការពារក្តី ខៀវ សំផន<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា | ១០.១៤<br>១០.១៧<br>១០.៥០ | ១០.១៥<br>១០.២១<br>១០.៥១ |
| ការប្រកាសផ្អាកសវនាការ | អង្គជំនុំជម្រះ | ១៣.៥១ | ១៣.៥៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>អង្គជំនុំជម្រះប្រកាសបើកសវនាការ</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកសវនាការ ហើយក្រឡាបញ្ជីប្រកាសវត្តមានរបស់ភាគី។ ប្រធានអង្គជំនុំជម្រះប្រកាសពីប្រវត្តិនីតិវិធីដោយសង្ខេបពាក់ព័ន្ធនឹងការចាត់តាំងមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន។

**<u>ការជំទាស់ទៅលើវត្តមាន និងការរៀបចំកន្លែងអង្គុយថ្មីរបស់មេធាវីប្រចាំការនៅក្នុងសវនាការ</u>**

មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងវត្តមានរបស់មេធាវីការពារក្តីនៅក្នុងបន្ទប់សវនាការ និងការរៀបចំកន្លែងអង្គុយថ្មីរបស់មេធាវីប្រចាំការ ហើយស្នើសុំអោយអង្គជំនុំជម្រះធ្វើការវិចារណាឡើងវិញពីសេចក្តីសម្រេចរបស់ខ្លួន។ មេធាវីការពារក្តី នួន ជា គាំទ្រទៅនឹងការជំទាស់នេះ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រទៅនឹងវត្តមានរបស់មេធាវីប្រចាំការ ដោយអះអាងការធ្វើដូច្នេះជាការចាំបាច់ក្នុងការធានាថាសវនាការប្រព្រឹត្តទៅដោយគ្មានការរាំងស្ទះ។ អង្គជំនុំជម្រះកត់សម្គាល់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី និងប្រកាសថាសេចក្តីសម្រេចនឹងចេញនៅពេលសមស្របខាងមុខ។

**<u>អង្គជំនុំជម្រះសួរបញ្ជាក់ពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ</u>**

ប្រធានអង្គជំនុំជម្រះសួបញ្ជាក់ទៅកាន់ជនជាប់ចោទ ខៀវ សំផន អំពីការប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ ជនជាប់ចោទទាំងពីររូប បញ្ជាក់ថាខ្លួនប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយជនជាប់ចោទ ខៀវ សំផន បញ្ជាក់ថាខ្លួនរក្សាសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍នៅពេលសមស្រប។

**<u>សំណើរបស់សហមេធាវីនាំមុខសុំឲ្យទទួលយកឯកសារផែនទី ជាភស្តុតាង</u>**

អង្គជំនុំជម្រះ និងមេធាវីអន្តរជាតិការពារក្ដី នួន ជា សួរឱ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹងសំណើរបស់ខ្លួនដែលបានស្នើដាក់ឯកសារផែនទី ដែលជាឯកសារថ្មី ចូលក្នុងសំណុំរឿង និងទទួលយកជាភ័ស្ដុតាង ដែលខ្លួនមានបំណងប្រើប្រាស់ក្នុងពេលស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-296។ ប្រធានអង្គជំនុំជម្រះប្រកាសថា អង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងសំណើនេះនៅមុនពេលស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-296។

**<u>ការតាំងសំណួរទៅកាន់សាក្សី មាស សុខា</u>**

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សី មាស សុខា។ បន្ទាប់មក សហព្រះរាជអាជ្ញាចាប់ផ្ដើមតាំងសំណួរ។

**<u>ការជំទាស់ទៅលើការអនុវត្តដែលឱ្យសាក្សីអានកំណត់ហេតុនៃការស្ដាប់ចម្លើយមុនការផ្ដល់សក្ខីកម្ម</u>**

មេធាវីការពារក្ដី ខៀវ សំផន ជំទាស់ទៅនឹងការអនុវត្តដែលអនុញ្ញាតិឱ្យសាក្សីអានកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ខ្លួនមុនពេលចូលមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះតម្រូវឱ្យមេធាវីការពារក្ដីដាក់នូវសេចក្ដីជំទាស់របស់ខ្លួនជាលាយលក្ខណ៍អក្សរ ហើយឱ្យបង្ហាញច្បាស់លាស់នូវកថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន។

**<u>ការប្រកាសផ្អាកសវនាការ</u>**

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីរហូតដល់ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥ ដោយសារមូលហេតុសុខភាពរបស់ជនជាប់ចោទ ខៀវ សំផន។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|
| E3/5825 | D25/31 | Written Record of Interview of MEAS Sokha | C | 00163511<br>00163512<br>00163513 | 00223494<br>00223495<br>00223496 | 00178111<br>00178112<br>00178112 |
| E3/5826 | D25/30 | Written Record of Interview of HUN Kimseng | C | 00163504 | 00223487 | 00178423 |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
| --- |
| • អង្គជំនុំជម្រះ បង្គាប់ឲ្យភាគីដាក់សំណើពាក់ព័ន្ធនឹងការអនុវត្តដែលអនុញ្ញាតិឲ្យសាក្សីអានកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ខ្លួនពីមុន មុនពេលផ្តល់សក្ខីកម្ម ជាលាយលក្ខណ៍អក្សរ ដោយបង្ហាញនូវកថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន។ <br> • បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥ និងបង្គាប់ឲ្យនាំខ្លួន ខៀវ សំផន មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥ ប្រសិនបើអាការៈគាត់បានប្រសើរឡើង។ |

| កាលវេលាសវនាការបន្ត |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីវហ៊ង Robbyne CROFT